**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ ១៧៨៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ ៥៦៥ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល។

**<u>សម្រេច</u>**

**មាត្រា១:** ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ជូនក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសាធារណការនិងដឹកជញ្ជូន ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ÷

www.pheakdeylaw.com

ឯកតា:លានរៀល

| ជំពូក | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | និយ័តកម្ម | | ឥណទានថ្មី |
|---|---|---|---|---|---|
| | | | កើន | ថយ | |
| | **និយ័តកម្មចេញ** | | | | |
| ២១ | ៩៩- ឥណទានមិនទាន់បែងចែក<br>អចលកម្មប្រើ | ៤១៧ ០៧៥ | | ១០០ ០០០ | ៣១៧ ០៧៥ |
| | **និយ័តកម្មចូល** | | | | |
| ២១ | ២០- ក្រសួងអភិវឌ្ឍន៍ជនបទ<br>អចលកម្មប្រើ | ១២០ ០០០ | ៥០ ០០០ | | ១៧០ ០០០ |
| | ២៥- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>អចលកម្មប្រើ | ២៤៥ ០០០ | ៥០ ០០០ | | ២៩៥ ០០០ |

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចមាត្រា ៣ .
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីគោរពជម្រាបជូន សម្តេចអគ្គមហាសេនាបតីតេជោ
នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

www.pheakdeylaw.com